# ការមិនទទួលខុសត្រូវ

គេហទំព័រនេះមិនសម្រាប់បុគ្គលទាំងឡាយណា ដែលត្រូវបានហាមឃាត់ក្នុងគ្រប់យុត្តាធិការ លើគ្រប់ហេតុផលនៃការបោះផ្សាយ ឬអាចប្រើបាននៃគេហទំព័រនេះ ដូចនេះអ្នកដែលគោរពតាមការហាមឃាត់ មិនត្រូវចូលទៅកាន់គេហទំព័រនេះទេ។ តាមការពិចារណារបស់ក្រុមហ៊ុន កូម៉ូ ធី ឯ.ក (តទៅហៅថា COMMO T) បានយល់ព្រមក្នុងការចូលទៅកាន់ការជួញដូរឧបករណ៍និស្សន្ទខាងក្រោមនេះ (តទៅហៅថាអតិថិជន)។ ព័ត៌មានខាងក្រោមនេះ មិនចាត់ទុកថាជាការផ្តល់ដំបូន្មានលើការវិនិយោគ ឬការផ្តល់អនុសាសន៍លើការ វិនិយោគសម្រាប់ការជួញដូរឧបករណ៍និស្សន្ទទាំងឡាយ ឬផលិតផលទាំងឡាយដែលបានផ្តល់ដោយ COMMO T។ មតិយោបល់ដែលបានបង្ហាញ មិនបានបង្ហាញពីគោលបំណងវិនិយោគ ស្ថានភាពហិរញ្ញវត្ថុ ឬតម្រូវការរបស់បុគ្គលជាក់លាក់ណាម្នាក់ឡើយ ដូចនេះវាមិនបង្កើតជាការប្រឹក្សាទាក់ទងនឹងផលិតផលវិនិយោគណាមួយឡើយ។ វិនិយោគិនទាំងអស់ត្រូវស្វែងរកការប្រឹក្សា ពីទីប្រឹក្សាហិរញ្ញវត្ថុដែលមានវិជ្ជាជីវៈត្រឹមត្រូវទៅតាមលក្ខណពិសេសរបស់បុគ្គលម្នាក់ៗ មុននឹងសម្រេចចិត្តក្នុងការវិនិយោគ ហើយគួរកំណត់ពីទំហំនៃការជួញដូរ និងអានុភាពនៃការជួញដូរទៅតាមហានិភ័យដែលកំណត់តាមការចង់បានផ្ទាល់ខ្លួន។ អតិថិជនបានទទួលស្គាល់ យល់ដឹង និងយល់ព្រមថា "ការជួញដូរគឺមិនអាចព្យាករណ៍បាន និងមានហានិភ័យខ្ពស់"។ ការជួញដូរឧបករណ៍និស្សន្ទ មានការប៉ាន់ស្មានខ្ពស់ដែលមិនអាចព្យាករណ៍បាន ហើយមានហានិភ័យក្នុងការខាតបង់ខ្ពស់ និងមិនសមស្របសម្រាប់វិនិយោគិនគ្រប់រូបនោះទេ ប៉ុន្តែសម្រាប់តែអតិថិជនដែល÷

- មានការយល់ដឹង និងមានឆន្ទៈក្នុងការសន្ទត់ហានិភ័យសេដ្ឋកិច្ច ច្បាប់ និងហានិភ័យដទៃទៀតដែលពាក់ព័ន្ធ
- មានបទពិសោធន៍ និងមានចំណេះដឹងអំពីការជួញដូរឧបករណ៍និស្សន្ទ និងនៅក្នុងប្រភេទនៃទ្រព្យសម្បត្តិមូលដ្ឋាន
- មានលទ្ធភាពផ្នែកហិរញ្ញវត្ថុ សម្រាប់ការខាតបង់យ៉ាងច្រើនលើសចំនួនកំណត់ ឬដាក់តម្កល់ ព្រោះវិនិយោគិនអាចនឹងខាតបង់តម្លៃសរុបនៃកិច្ចសន្យា មិនត្រឹមតែប្រាក់ដែលបានកំណត់ ឬប្រាក់ដែលបានដាក់តម្កល់នោះទេ។

ការជួញដូរឧបករណ៍និស្សន្ទ គឺជាការវិនិយោគសមស្របសម្រាប់មូលនិធិសោធននិវត្តន៍ ហើយប្រតិបត្តិការរបស់វាស្ថិតក្នុងចំណោមប្រភេទនៃការវិនិយោគដែលមានគ្រោះថ្នាក់បំផុត ហើយអាចបណ្តាលឱ្យមានការខាតបង់ច្រើន។ អតិថិជន បានអះអាង ធានា និងយល់ស្របថា អតិថិជនបានយល់ដឹងអំពីហានិភ័យទាំងនេះ ព្រមទាំងមានឆន្ទៈ និងមានលទ្ធភាពហិរញ្ញវត្ថុ ហើយអាចសន្ទត់ពីហានិភ័យនៃការជួញដូរឧបករណ៍និស្សន្ទ និងការខាតបង់តុល្យភាពទាំងស្រុងនៃគណនីរបស់អតិថិជននឹងមិនផ្លាស់ប្តូរឥរិយាបទនៃការរស់នៅរបស់អតិថិជននោះឡើយ។

COMMO T មិនអះអាង ឬធានាអំពី÷

- រាល់ទិន្នន័យ និងឯកសារដែលមាននៅលើគេហទំព័រនេះ
- រាល់សេវាកម្មវិនិយោគដែលអាចត្រូវបានចាត់ទុកថាមាននៅលើគេហទំព័រនេះ
- អ្វីគ្រប់យ៉ាងដែលមាននៅលើគេហទំព័រនេះ គឺសមស្របសម្រាប់ការប្រើប្រាស់ ឬត្រូវបានអនុញ្ញាតដោយច្បាប់ និងគោលការណ៍ជាតិដែលអាចអនុវត្តបាននៅគ្រប់ដែនសមត្ថកិច្ចទាំងអស់។

អតិថិជនយល់ថាឧបករណ៍និស្សន្ទអាចត្រូវបានទូទាត់ដោយសាច់ប្រាក់សុទ្ធ និងភាពខុសគ្នារវាងតម្លៃទិញ និងតម្លៃលក់មិនកំណត់ពីលទ្ធផលនៃការវិនិយោគនោះទេ។ ការវិនិយោគលើឧបករណ៍និស្សន្ទ ជាមួយនឹងការចុះបញ្ជីរូបិយប័ណ្ណខុសគ្នារវាងទ្រព្យសម្បត្តិមូលដ្ឋាន និងរូបិយប័ណ្ណគោលអាចបង្កើតជាហានិភ័យ ដោយសារនៅពេលដែលធ្វើការទូទាត់លើឧបករណ៍និស្សន្ទដែលមានរូបិយប័ណ្ណខុសពីរូបបិយប័ណ្ណគោលរបស់អតិថិជន នោះតម្លៃនៃការទទួលបានត្រឡប់មកវិញរបស់អតិថិជនអាចរងផលប៉ះពាល់ដោយអត្រាប្តូរប្រាក់ទៅជារូបិយប័ណ្ណគោលនោះ។

ប្រព័ន្ធជួញដូរអេឡិចត្រូនិចរបស់ COMMO T ផ្តល់នូវការបញ្ជូនការបញ្ជាទិញរបស់អតិថិជនភ្លាមៗនៅពេលដែលអតិថិជនបានកំណត់ចំនួននៃការវិនិយោគ ហើយចុច “ទិញ ឬលក់”។ នេះមានន័យថា វាគ្មានលិទ្ធភាពក្នុងការត្រួតពិនិត្យមើលសារឡើងវិញបន្ទាប់ពីចុច “ទិញ ឬលក់” នោះទេ ហើយការបញ្ជាទិញនៅលើទីផ្សារក៏មិនអាចលុបចោល ឬកែប្រែបានដែរ។ លក្ខណពិសេសនេះអាចមានភាពខុសគ្នាពីប្រព័ន្ធជួញដូរដទៃដែលអតិថិជនធ្លាប់បានប្រើ។ អតិថិជនគួរប្រើប្រាស់ប្រព័ន្ធជួញដូរសាកល្បង ដើម្បីស្គាល់ច្បាស់ និងស៊ាំជាមួយនឹងប្រព័ន្ធជួញដូរអេឡិចត្រូនិចរបស់ COMMO T មុននឹងចាប់ផ្តើមធ្វើការជួញដូរតាមប្រព័ន្ធអេឡិចត្រូនិចពិតប្រាកដ។ តាមរយៈការប្រើប្រាស់ប្រព័ន្ធជួញដូរអេឡិចត្រូនិចរបស់ COMMO T អតិថិជនបានយល់ស្រប ទទួលស្គាល់ និងយល់ដឹងច្បាស់ជាមួយនឹងការប្រើប្រាស់ប្រព័ន្ធចុចតែម្តងបញ្ជូន (one-click system) និងយល់ព្រមទទួលយករាល់ហានិភ័យដែលអាចកើតមាននៃមុខងារបញ្ជូន ឬប្រតិបត្តិការភ្លាមៗនេះ។

នៅពេលដែលអតិថិជនធ្វើការជួញដូរតាមប្រព័ន្ធអេឡិចត្រូនិច (តាមរយៈអ៊ីនធឺណិត) COMMO T មិនទទួលខុសត្រូវចំពោះការទាមទារ ការខាតបង់ ការខូចខាត ការចំណាយ ដែលកើតឡើងដោយចំពោះ ឬមិនចំពោះដែលបណ្តាលមកពីការដំណើរការមិនប្រក្រតី ការរំខាន ឬការបញ្ជូនបរាជ័យ ប្រព័ន្ធទំនាក់ទំនង គ្រឿងឧបករណ៍កុំព្យូទ័រ ឬកម្មវិធីជួញដូរ ដែលជាកម្មសិទ្ធិរបស់ COMMO T របស់អតិថិជន ឬប្រព័ន្ធនៃការផ្លាស់ប្តូរ ឬប្រព័ន្ធនៃការដោះស្រាយ ឬប្រព័ន្ធនៃការទូទាត់ទាំងឡាយនោះទេ។

ការប្រឹក្សាទីផ្សារទូទៅដែលផ្តល់ឱ្យដោយ COMMOT គឺផ្អែកទៅលើមូលដ្ឋាននៃការវិនិច្ឆ័យរបស់បុគ្គលិក COMMO T និងអាចយកទៅពិចារណាបាន។ អតិថិជនបានយល់ និងទទួលស្គាល់ថាការធ្វើប្រតិបត្តិការទាំងឡាយណារបស់អតិថិជនគឺផ្អែកលើការវិនិច្ឆ័យផ្ទាល់ខ្លួនរបស់អតិថិជន។ រាល់ការផ្តល់ការប្រឹក្សាទីផ្សារ គឺជាការផ្តល់ទូទៅតែប៉ុណ្ណោះ ហើយអាចនឹងមិនស្របជាមួយនឹងទីផ្សារជាក់ស្តែង ឬចេតនារបស់ COMMO T និងដៃគូរនោះទេ។ ការផ្តល់អនុសាសន៍ទីផ្សារទូទៅរបស់ COMMO T ផ្អែកលើព័ត៌មាន និងទិន្នន័យដែលជឿជាក់ថាអាចទុកចិត្តបាន តែ COMMO T មិនអាច និងមិនធានានូវភាពត្រឹមត្រូវ និងភាពពេញលេញ ឬបង្ហាញថាការធ្វើតាមការប្រឹក្សាទីផ្សារនេះនឹងលុបបំបាត់ ឬកាត់បន្ថយនូវហានិភ័យដែលកើតមានក្នុងការជួញដូរឧបករណ៍និស្សន្ទនោះទេ។ ក្រៅពីនោះ COMMO T នឹងមិនធានាពីផលចំណេញ និងការខាតបង់ដែលកើតមានក្នុងការជួញដូរឧបករណ៍និស្សន្ទនោះដែរ។ អតិថិជននឹងមិនទទួលបាននូវការធានាទាំងនេះពី COMMO T និងអ្នកតំណាងណាមួយឡើយ។ អតិថិជនបានដឹងពីហានិភ័យទាំងឡាយដែលកើតមានឡើងក្នុងការជួញដូរឧបករណ៍និស្សន្ទ និងមានលទ្ធភាពផ្នែកហិរញ្ញវត្ថុគ្រប់គ្រាន់ ដែលអាចប្រឈមនឹងហានិភ័យ និងការទប់ទល់នឹងការខាតបង់ទាំងឡាយដែលកើតមានឡើង។

COMMO T មិនទទួលខុសត្រូវចំពោះបញ្ហា quoting error ដែលកើតមានឡើង (រួមទាំងការឆ្លើយតបទៅកាន់ការស្នើសុំរបស់អតិថិជន) ដូចជាបញ្ហាដែលកើតមានឡើងចំពោះសមតុល្យគណនី និងសិទ្ធិក្នុងការកែតម្រូវចាំបាច់ ឬការកែប្រែផ្សេងៗដែលពាក់ព័ន្ធជាមួយនឹងគណនី។ រាល់វិវាទទាំងឡាយដែលកើតមានឡើងពីបញ្ហា quoting errors នឹងត្រូវដោះស្រាយដោយផ្អែកលើតម្លៃទីផ្សារសមរម្យនៅអំឡុងពេលដែលកំហុសនោះកើតឡើង តាមការកំណត់របស់ COMMO T ដោយការសម្រេចចិត្ត និងប្រតិបត្តិដោយស្មោះត្រង់។ ក្នុងករណីដែលទីផ្សារជាក់ស្តែងបង្ហាញតម្លៃខុសពីតម្លៃរបស់ COMMO T ដែលបានដាក់បង្ហាញជាផ្លូវការ នោះ COMMO T នឹងព្យាយាមធ្វើប្រតិបត្តិការលើតម្លៃដែលប្រហាក់ប្រហែលនឹងតម្លៃទីផ្សារជាក់ស្តែង។ តម្លៃទីផ្សារជាក់ស្តែងនេះនឹងជាតម្លៃដែលបង្ហាញនៅក្នុងរបាយការណ៍ចុងក្រោយរបស់អតិថិជន។ នេះអាចនឹងមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការចំណេញ ឬការខាតបង់របស់អតិថិជន។

ការប្រើប្រាស់គេហទំព័រនេះរបស់អតិថិជន ត្រូវបានគ្រប់គ្រងដោយលក្ខខណ្ឌនៃការប្រើប្រាស់ ហើយនឹងមានប្រសិទ្ធិភាពនៅកាលបរិច្ឆេទដែលអតិថិជនបានចូលទៅប្រើប្រាស់គេហទំព័រនេះ។ ព័ត៌មានដែលមាននៅលើគេហទំព័រនេះ គឺជាព័ត៌មានជាក់ស្តែង តាមកាលបរិច្ឆេទដែលបានបោះផ្សាយ ប៉ុន្តែ COMMO T សូមរក្សាសិទ្ធិក្នុងការកែប្រែព័ត៌មានទាំងឡាយនៅក្នុងគេហទំព័រនេះ ក៏ដូចជាលក្ខខណ្ឌនៃការប្រើប្រាស់ដោយពុំបាច់ជូនដំណឹងជាមុន។ ក្នុងករណីដែលអតិថិជនបានប្រើប្រាស់គេហទំព័រនេះបន្ទាប់ពីលក្ខខណ្ឌក្នុងការប្រើប្រាស់ត្រូវបានធ្វើវិសោធនកម្មត្រូវបានបោះផ្សាយនោះ អតិថិជននឹងចាត់ទុកថាបានយល់ព្រមតាមលក្ខខណ្ឌនៃការប្រើប្រាស់ថ្មីដែលបានកែប្រែនោះ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់យើងខ្ញុំតាមរយៈសារអេឡិចត្រូនិច info@commot.asia ៕